ខុមហ្វ្រែល COMFREL

# ព័ត៌មាន (News)

## ការផ្តល់សិទ្ធិអំណាចយុវជន

គឺជាគម្រោងថ្មីមួយរបស់ខុមហ្វ្រែលដែលគាំទ្រដោយអង្គការOXFAM ដើម្បីផ្តល់សិទ្ធិអំណាចដល់យុវជនទីប្រជុំជន ជាពិសេសជនចំណាកស្រុក និងស្រ្តី ដើម្បីឲ្យពួកគេដឹង ទាមទារ និងលើកកម្ពស់សិទ្ធិរស់នៅប្រកបដោយនិរន្តរភាព មានស្ថានភាពរស់នៅសមរម្យ និងមានសុវត្ថិភាព។

នៅថ្ងៃទី២០-២២ ខែមករា ឆ្នាំ២០១៥ ខុមហ្វ្រែលសហការជាមួយ Butterfly Works បានរៀបចំសិក្ខាសាលាស្តីពីការប្រមូលផ្តុំគំនិតនិងសហការបង្កើតយុទ្ធនាការ នៅឯការិយាល័យរបស់អង្គការOXFAM ដើម្បីចែករំលែករបៀបក្នុងការធ្វើយុទ្ធនាការ offline/online ហើយនិងដើម្បីផ្តល់ឱកាសដល់យុវជនលើកនូវគំនិតថ្មីៗក្នុងការធ្វើយុទ្ធនាការក្នុងចំណោមយុវជនដូចគ្នា។ នៅក្នុងសិក្ខាសាលាមានអ្នកសម្របសម្រួល២នាក់មកពីប្រទេសហូឡង់ និងមានអ្នកចូលរួម៣២នាក់(១៤នាក់ជាស្រ្តីវ័យក្មេង) មកពីអង្គការយុវជននិងបណ្តាញយុវជន។ ជាលទ្ធផលនៃសិក្ខាសាលា យុវជនបានយល់ដឹងពីឧបករណ៍និងយុទ្ធសាស្រ្តដើម្បីធ្វើយុទ្ធនាការoffline/online ។

## Urban Youth Empowerment

is a new project of COMFREL supported by OXFAM to empower urban youth, especially migrants and women to recognize, claim and uphold their rights to a sustainable livelihood, decent living conditions and a safe and inclusive city.

On 20-22 January 2015, COMFREL in cooperation with Butterfly Works organized a three-day workshop with on “Co-Creating a Campaign Platform” at Oxfam’s office to share experiences how to do offline/online campaign as well as come up with new idea of doing the campaign amongst of youth. There were two facilitators from Netherlands and 32 participants (14 young women) from youth organizations and youth network. As a result, youth understood the tools and strategies to do offline and online campaign.





